ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៩...អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

# សម្រេច

**មាត្រា ១.-** តែងតាំងមន្ត្រីរាជការចំនួន ១២ រូប របស់ក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក **ថុល ណារ៉ា** | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ |
| ២- លោក **ឡុង កែមវិចិត្រ** | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ |
| ៣- លោក **ហាស់ ម៉េងហុង** | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ |
| ៤- លោក **ឌិត រិទ្ធីពល** | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ |

៥- លោក **សុខ ដារិទ្ធ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

៦- លោក **អួច សុខន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

៧- លោកស្រី **ឃឹម កញ្ញា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៨- លោក **ហុង បញ្ញារិទ្ធ** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន

៩- លោក **គិត តាវ៉ា** សម្រួលភារកិច្ចពីប្រធាននាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម ទៅជាប្រធាននាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

១០- លោក **ឈាង ផា** សម្រួលភារកិច្ចពីប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ ទៅជាប្រធាននាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

១១- លោក **អ៊ឹម កុយ** ជាប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

១២- លោក **ឡុង ភាណាបុត្រ** ជាប្រធាននាយកដ្ឋានអាមេរិក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣ កើត ខែ បុស្ស ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*